# ចាចាមនុស្សលោក

បទព្រហ្មគីតិ

លោកនេះសែនចំលែក　　គន់គាប់ភ្នែកគាប់ចិន្តា
ល្អល្អះឥតសង្កា　　ស្តាប់វាចាគួរីករាយ ។
ផ្ទៀងសោតស្តាប់សំដី　　ជនប្រុសស្រីពោលស្វាធ្យាយ
ខ្លឹមសាររៀបរៀងរាយ　　កបប្រយោជន៏ស្រោចសព្វសារ ។
ពាក្យពេចន៏ដែលមនុស្សពោល　　ជាពំនោលគួរជ្រះថ្លា
ម្នាក់ៗស្អប់ណាស់ណា　　ឫកឫស្យាក្នុងសន្តាន ។
ស្អប់ណាស់អយុត្តិធមិ　　មិនបវរនាំរំខាន
រង្កៀសឫកតិរច្ឆាន　　រឿងមិនក្សាន្តមិនចង់យល់ ។
ស្អប់កម្មអបាយមុខ　　មិនសាងទុក្ខរឿងរាំងជល់
ស្អប់កម្មមិននិមល　　ស្អប់ឫសគល់គ្រប់បញ្ហា ។
ស្រលាញ់សន្តិភាព　　មិនលោភលាភយសសក្តា
មិនតំកើងអាត្មា　　មិនចរចាពាក្យញុះញង់ ។
ស្រលាញ់រឿងនិរទោស　　មិនចង់ខុសស្លុះអន្លង់
ស្អប់បាត់ចង់បានគង់　　ស្អប់ក្តីល្ងង់ចង់បានចេះ ។
ស្អប់ល្បែងល្បិចកិច្ចកល　　អកុសលរឿងមិនខ្មេះ
គ្រប់គ្នាពោលដូច្នេះ　　ផ្លូវមិនផេះមិនចេះថា ។
ជនគ្រប់ជាន់វណ្ណៈ　　ចោរអបល័ក្ខណ៏ ពាលឫស្យា
មន្ត្រីខ្ញុំរាជការ　　សឹងវាចាលើកច្បាប់ក្បួន ។
បើធ្វើដូចវាចា　　ម្ល៉េះលោកាសុខសមសួន
គ្មានឈ្លោះគ្មានគុំគួន　　សុខផ្លូនៗគ្មានវេរា ។

Ca. ០៦ ឧសភា ២០០៦